JOB TRAINING + Education

## សេវាកម្មបណ្តុះបណ្តាលអំពីការងារ និងការស្វែងរកការងារ

**តើអ្នកកំពុងចាប់ផ្តើម និងពង្រីកសកម្មភាពអាជីវកម្មខ្នាតតូចមែនទេ ?**

**តើអ្នកចាប់អារម្មណ៍ចង់រៀនអំពីកសិកម្មដែរឬទេ ?**

**តើអ្នកត្រូវការជំនួយ ដើម្បីទទួលបាន GED របស់ខ្លួនមែនទេ ?**

**ប្រសិនបើចំលើយរបស់អ្នកចំពោះសំណួរខាងលើ គឺបាទ/ចាស៎ CTI អាចជួយដល់អ្នកបាន ។**

**មជ្ឈមណ្ឌលគាំទ្រដល់អាជីវកម្មធុនតូចឡូវែល (LSBAC)** - ជាមជ្ឈមណ្ឌលដែលផ្តល់ដល់សហគ្រិនដែលមកពីក្រុមជាតិសាសន៏ និងអ្នកមានកំរិតជីវភាពផ្សេងៗគ្នា នូវការអប់រំ វិធីសាស្រ្ត និងធនធានដែលចាំបាច់សំរាប់ការបង្កើត ពង្រឹង និងពង្រីកអាជីវកម្មខ្នាតតូច ដើម្បីជាជំនួយ និងធ្វើអោយអោយអាជីវកម្មមានស្រាប់បានរឹងមាំ និងរីកចំរើនតាមរយៈការអប់រំ និងការគាំទ្រខាងបច្ចេកទេស ។ មជ្ឈមណ្ឌលយើង មានកម្មវិធីបង្រៀនមួយឈ្មោះថា "Right Start" ដែលនឹងផ្តល់អោយអ្នកនូវចំណេះដឹងគ្រឹះក្នុងការធ្វើផែនការ កសាង និងពង្រីកអាជីវកម្មរបស់អ្នក ។ មជ្ឈមណ្ឌលយើង សំបូរដោយធនធាន ឧបករណ៍ និងសេវាកម្មគាំទ្រដើម្បីជួយអោយអ្នកអាចធ្វើការចាប់ផ្តើមបាន។ សំរាប់ពត៌មានបន្ថែម សូមទំនាក់ទំនង ទូរស័ព្ទលេខ (978) 322-8400 ឬអានគេហទំព័រ www.lowellsbac.org ។

**គំរោងដាំដុះប្រកបដោយនិរន្តរភាពសំរាប់ការចូលថ្មី (NESFP)** - ជាកម្មវិធីបណ្តុះបណ្តាល និងគាំទ្រផ្នែកបច្ចេកទេសសំរាប់ជនអន្តោប្រវេសន៏ និងអ្នកភៀសខ្លួន ដើម្បីជួយបង្កើតកសិករជំនាន់ថ្មីនៅក្នុងរដ្ឋម៉ាសាជូសែត ។ កម្មវិធីនេះ ផ្តល់ការបណ្តុះបណ្តាលអំពីកសិកម្មនៅប៉ែកឥសាននៃប្រទេស អំពីការធ្វើផែនការអាជីវកម្មក្នុងរបរកសិកម្ម និងមានរយៈពេលដល់ទៅបីឆ្នាំ នៅនឹងកសិដ្ឋានសំរាប់ការហាត់រៀននៅ Lowell, Fitchburg និង Worcester ដោយមានគោលបំណងដើម្បីជួយអោយអ្នក ក្លាយជាកសិករថ្មីប្រកបដោយជោគជ័យម្នាក់ ។ អ្នកត្រូវតែជាជនអន្តោប្រវេសន៏ ឬអ្នកភៀសខ្លួន និងធ្លាប់មានបទពិសោធន៏លើវិស័យកសិកម្មនៅប្រទេសកំណើតរបស់ខ្លួន ឬនៅសហរដ្ឋអាមេរិក ដើម្បីអាចចូលរៀនក្នុងវគ្គបណ្តុះបណ្តាលនេះបាន ។ សំរាប់ពត៌មានបន្ថែម សូមទំនាក់ទំនងទូរស័ព្ទលេខ (978) 654-6745 ឬ (617) 636-3793 ។

**YouthBuild** - កម្មវិធី YouthBuild របស់ CTI ផ្តល់ការបណ្តុះបណ្តាល និងការអប់រំក្នុងការរកការងារធ្វើអោយដល់យុវជនដែលមានអាយុចាប់ពី ១៧ ដល់ ២៤ ឆ្នាំ ដែលឈប់ពីការសិក្សានៅសាលា និងមិនមានការងារធ្វើ ។ កម្មវិធីបណ្តុះបណ្តាលពេញម៉ោងនេះ ផ្តល់ដល់សិក្ខាកាមនូវឱកាសដើម្បីទទួលបាននូវ GED និងក្លាយជាអ្នកមានជំនាញផ្នែកពាណិជ្ជកម្មសំណង់ ។ សំរាប់ពត៌មានបន្ថែម សូមទំនាក់ទំនងទូរស័ព្ទលេខ (978) 446-9803 ។

**ថ្នាក់រៀន GED និង ESL** - គឺជាថ្នាក់បរៀន រៀបចំឡើងនៅទីតាំងបីកន្លែងរបស់ CTI ។Milly's Place ដែលមានទីតាំងនៅ 360 Pawtucket St., Lowell, the Houlares Early Education Center (អតីត Head Start Building) ដែលមានទីតាំងនៅ 126 Phoenix Ave, Lowell និងកម្មវិធី YouthBuild របស់ CTI ដែលមានទីតាំងនៅ 391 Pawtucket St., Lowell មានបើកថ្នាក់បង្រៀន GED នៅក្នុងបរិយាកាសសមស្របសំរាប់សិស្សដែលចុះឈ្មោះចូលរៀនក្នុងកម្មវិធី ។ សំរាប់ពត៌មានបន្ថែម សូមទំនាក់ទំនងទូរស័ព្ទលេខ (978) 452-4241 ឬ (978) 454-5100 ។